00157065

**Declassified to Public**
**06 September 2012**

D25/2/2

ORIGINAL DOCUMENT RECEIVED ON 28/12/2007 AT 13:00' BY NUP SOTHEAVUTHET ACTING CASE FILE OFFICER

**Kingdom of Cambodia**
**Nation Religion King**

Extraordinary Chambers in the Courts of Cambodia

| |
|---|
| **បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម** |
| **Certified Copy/Copie Conforme** |
| ថ្ងៃទី(On/Le)..28...ខែ(Month/Mois)..Dec.. |
| ឆ្នាំ (Year/Année).........2007............ |
| ក្រឡាបញ្ជី/ Greffier ...SANN...RADA... |

ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ជម្រាបមក

**-ឈ្មោះ ឈិន ណារី**

**-អាសយដ្ឋាន:** សមាគម អាដហុក ផ្ទះលេខ៣ ផ្លូវ១៥៨ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ

**-អ៊ីម៉ែល:** adhoc@forum.org.kh

**-កាលបរិច្ឆេទនៃការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត:** ០៨ វិច្ឆិកា ២០០៧

**-លេខសំណុំរឿងយោង:** **001/18-07-2007-ECCC-OCIJ** និង **002/19-09-2007-ECCC-OCIJ**

**កម្មវត្ថុ៖ ស្ថានភាពនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណីរបស់លោក-លោកស្រី**

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានទទួលដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ កាលពីថ្ងៃខែឆ្នាំខាងលើ ហើយ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងយោងលេខ **001/18-07-2007-ECCC-OCIJ** ក្រោមលេខ **D25/2** នៅថ្ងៃដដែលផងដែរ។ ក្រោយពីការិយាល័យសហចៅក្រមស៊ើបអង្កេតបានពិនិត្យលើពាក្យសុំរបស់លោក-លោកស្រី

លោក-លោកស្រី ត្រូវបានជូនដំណឹងតាមរយៈសមាគមអាដហុក អំពីលទ្ធភាពចូលរួមនៅក្នុងការស៊ើបអង្កេតរបស់តុលាការមួយផ្សេងទៀត។ តាមរយៈការពិនិត្យលើចម្លើយតបរបស់លោក-លោកស្រី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងយោងលេខ **002/19-09-2007-ECCC-OCIJ** ក្រោមលេខ **D22/6** នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ផងដែរ។



CO-INVESTIGATING JUDGES GREFFIER * CO-JUGES D'INSTRUCTION * E.C.C.C. * C.E.T.C.

00157066

D25/2/2

ហេតុដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត (សូមអានកថាខណ្ឌទី ២) លោក-លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងរឿងក្តីទាំងពីរនេះ។

សូមរំលឹកថា នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត អាចធ្វើសេចក្តីសម្រេចផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក-លោកស្រី ដែលអាចជា ការសម្រេចយល់ព្រម ឬបដិសេធ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា លោក-លោកស្រី មិនមែនជាជនរងគ្រោះ ឬថាលក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មិនត្រូវបានបំពេញ។ សេចក្តីសម្រេចបែបនេះ គឺបើកឲ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

លោក-លោកស្រី ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក-លោកស្រី អាចដឹងអំពីព័ត៌មានសម្ងាត់នានាដែលមាននៅក្នុងសំណុំរឿង។ មានតែចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ប៉ុណ្ណោះ ដែលអាចសម្រេចផ្តល់ព័ត៌មានទាំងនោះជាសាធារណៈ។ លោក-លោកស្រី មានកាតព្វកិច្ចរក្សាការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ដោយមិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ទាំងនេះឡើយ លើកលែងតែព័ត៌មានផ្ទាល់ខ្លួនណាដែលលោក-លោកស្រី បានផ្តល់ជូនចៅក្រមនៅក្នុងការដាក់ពាក្យសុំរបស់លោក-លោកស្រី។

ប្រសិនលោក-លោកស្រី ត្រូវការការណែនាំបន្ថែម ទាក់ទិននឹងការចូលរួមរបស់លោក-លោកស្រី នៅក្នុងនីតិវិធីតុលាការ សូមធ្វើទំនាក់ទំនងមកកាន់អង្គភាពគាំពារជនរងគ្រោះ។ វិធាន និង សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. អាចពិគ្រោះ និងថតចម្លងទុកបាន ពីគេហទំព័រនៃអង្គភាពគាំពារជនរងគ្រោះ (www.eccc.gov.kh)។

សូមលោក-លោកស្រី ទទួលនូវការរាប់អានអំពីយើងខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧

ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត

CO-INVESTIGATING JUDGES GREFFIER "CO-JUGES D'INSTRUCTION" E.C.C.C. C.E.T.C.

LY Chantola ចាម ហ៊ើល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។